# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការលាលាឧទ្ធរណ៍
លេខ ៣៥៦/០៣

## អគ្គព្រះរាជអាជ្ញា មហាអយ្យការសាលាឧទ្ធរណ៍

## ជូនលោកព្រះរាជអាជ្ញាតុលាការខេត្ត-ក្រុង

***កម្មវត្ថុ:*** អំពីភារៈកិច្ចចង្អុលភស្តុតាង ។

តាមការសង្កេត លើសំណុំរឿងព្រហ្មទណ្ឌប្តឹងឧទ្ធរណ៍ ខ្ញុំបានកត់សម្គាល់ឃើញមានការខ្វះខាតក្នុងភារៈកិច្ចមួយដែលជាផលវិបាកធ្ងន់ធ្ងរក្នុងការទទួលខុសត្រូវរបស់អស់លោកអយ្យការ ជាព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងក្នុងការចោទប្រកាន់គឺការចង្អុលភស្តុតាង ។

លោកព្រះរាជអាជ្ញា លោកព្រះរាជអាជ្ញារងបានធ្វើដីកាសន្និដ្ឋានចោទប្រកាន់សុំអោយចៅក្រមស៊ើបសួរ ឬធ្វើដីកាសន្និដ្ឋានស្ថាពរសុំអោយបញ្ជូនជនល្មើសទៅតុលាការជំនុំជម្រះដីកាសន្និដ្ឋានទាំងនេះ ត្រូវតែធ្វើសេចក្តីសំយោគផ្តេកផ្តួលលើភស្តុតាងជាដរាប ។ ភស្តុតាងទាំងនេះត្រូវជាភស្តុតាងទាក់ទងនិងធាតុផ្សំនៃបទល្មើសដែលមានធាតុសម្ភារៈដែលជាអំពើស្តែងចេញជាការប្រព្រឹត្តអំពើជាក់ស្តែង ឬក៏អាចជាអំពើអសកម្មដែរ ធាតុចេតនាក្នុងការប្រព្រឹត្តិបទល្មើស ធាតុបញ្ញត្តិច្បាប់ចែងអំពីបទល្មើស អំពើទោស និងអាចមានធាតុផ្សំផ្សេងទៀត ទៅតាមគោលការណ៍នៃច្បាប់បានចែងហើយនិងត្រូវគិតអំពីស្ថានទម្ងន់ ស្ថានសម្រាលផងដែរ សរុបសេចក្តីទៅអយ្យការត្រូវចង្អុលភស្តុតាងជាដរាបពីព្រោះអយ្យការជាអ្នកចោទប្រកាន់ ភាគីដើមដែលច្បាប់បានប្រគល់អំណាចជូនដូចជាមាត្រា ១៣១ នៃរដ្ឋធម្មនុញមាត្រា២.៣.៤.៨.៤៩ និងតទៅនៃច្បាប់នីតិវិធីព្រហ្មទណ្ឌត្រូវមានភស្តុតាងជាបង្អែកជាមូលដ្ឋានសំអាងដើម្បីជៀសវាងរបៀបចោទប្រកាន់ដោយរំលោភអំណាច ។ការចោទប្រកាន់អាស្រ័យដោយភស្តុតាងសព្វគ្រប់នេះមានគោលដៅជាចម្បង គឺសុំអោយតុលាព្រហ្មទណ្ឌផ្តន្ទាទោសជនល្មើសដែលត្រូវទទួលខុសត្រូវជាប់ពន្ធនាគារ ត្រូវកែប្រែគំនិតមាយាទ ដើម្បីក្លាយជាប្រជាពលរដ្ឋល្អ អាចត្រឡប់ទៅរួមរស់ក្នុងសង្គមវិញក្នុងពេលអនាគត ។

ដូច្នេះ ដើម្បីអាចមានភស្តុតាង ធួនល្មម (ពាក្យប្រើក្នុងដីកា ឬសាលក្រម) នៅពេលសវនាការនៃតុលាការហើយទទួលថាធួនល្មមមែននោះ ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងដែលជាអ្នកទទួលភារៈកិច្ចត្រូវស្វះស្វែង តាំងពីដំណាក់កាលនៃអំពើប្រព្រឹត្តភ្លាមៗ ដែលអាចអោយតម្លៃជាអំពើជាក់ស្តែង (កំណត់ហេតុត្រូវតែឆ្លុះបញ្ចាំងលក្ខខ័ណ្ឌជាក់ស្តែងផង) ហើយអន្តរាគមរបស់មន្ត្រីនគរបាលយុត្តិធម៌មានសារៈសំខាន់ណាស់ ចំណែកឯវត្តមានរបស់ព្រះរាជអាជ្ញាព្រះរាជអាជ្ញារង ក៏មានសារៈសំខាន់ដែរ ដែលមានភារៈកិច្ចដឹកនាំមន្ត្រីនគរបាលដទៃទៀត តាមបញ្ញត្តិមាត្រា ៣៦ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ដើម្បីប្រមូលភស្តុតាង សំណៅភស្តុតាងផ្សេងៗ ពាក់ព័ន្ធនឹងជនល្មើសដើម្បីការពារកុំអោយបាត់ កុំអោយបំបាត់ កុំអោយវិនាសទៅវិញ ឬបំផ្លាញទៅវិញ ហើយភស្តុតាង ភស្តុតាងទាំងនេះមានដូចជា អាវុធកាំភ្លើង គ្រាប់កាំភ្លើង កាំបិត ពូថៅ ប្រដាប់ប្រដាវត្ថុផ្សេងៗ ស្នាមដានជើង ខ្មៅដៃ ឈាម ទឹកកាម ទឹកមាត់ ទឹកភ្នែកសក់ រោម ឬ ស្បែករបក ។ល ។ ដែលនឹងត្រូវពង្រឹង និងស្វែងរកទំនាក់ទំនងជាមួយជនល្មើសដោយអ្នកបច្ចេកទេសនៅពេលបន្តបន្ទាប់ក្នុងដំណាក់កាលស៊ើបអង្កេតដោយចៅក្រម ព្រមទាំងឃាត់ខ្លួនជនល្មើសដែលពាក់ព័ន្ធ ។ ខ្ញុំសូមផ្ញើតទាក់ទាញអារម្មណ៍ថា លោកព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ត្រូវប្រុងប្រយ័ត្ន និងគ្រោងថានៅដំណាក់កាលផ្សេងៗទៅអនាគតអាចមានការប្រើមធ្យោបាយ កែក្រឡះសភាពដើមនៃភស្តុតាង ឬចង្អុលភស្តុតាងផ្ទុយ ។

ដូច្នេះភស្តុតាងត្រូវតែរឹងមាំ ឬស្វែងរកចំណុចរឹងមាំមិនអាចអោយកែប្រែបាន ។ ដូច្នេះភស្តុតាងដែលប្រមូលបានដែលស្រាវជ្រាវរកឃើញជាបន្តបន្ទាប់ ត្រូវតែលោកព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ការពារតាមការពារនៅគ្រប់

ដំណាក់កាលទោះជាក្នុងពេលសវនាការ នៃតុលាការ ក៏ត្រូវតែការពារដែរដោយគិតថា ភស្តុតាងភាគច្រើនមានតម្លៃរហូតដល់មានភស្តុតាងផ្ទុយ ដូចមានចែងបញ្ជាក់ក្នុងបញ្ញត្តិមាត្រា៤២ នីតិវិធីព្រហ្មទណ្ឌថ្ងៃ១៣-០១-៩៣ និងមាត្រា ២៤ នីតិវិធី អន្តរកាល ហើយភស្តុតាងផ្ទុយ គឺជាភស្តុតាងប្រភេទជាភស្តុតាងពុំមែនជាចម្លើយបដិសេធរបស់ជនល្មើសពេលសវនាការ ពេលសួរចម្លើយដែលមិនត្រូវទទួលស្គាល់ជាភស្តុតាងផ្ទុយគ្រប់គ្រាន់បាន ចម្លើយទាំងនេះមានតម្លៃជាព័ត៌មាន ឬក៏ជាលំនាំដើមដើម្បីអាចស្វែងរកភស្តុតាងផ្ទុយប៉ុណ្ណោះ ពីព្រោះបើមិនប្រកាន់ដូច្នេះទេនោះមានការទាត់ចោលលទ្ធផលស៊ើបអង្កេតពីដំបូងនិងនៅដំណាក់កាលចៅក្រមស៊ើបអង្កេត ហើយគិតថាគ្មានតម្លៃទុកជាអសាឥតការ ហើយមកគិតតែអំពីចម្លើយពេលសវនាការចុងក្រោយនេះជាមានតម្លៃប៉ុណ្ណោះ ។

ម្យ៉ាងទៀត ខ្ញុំសូមលោកព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងផ្តល់តម្លៃដល់ការងារចុះស៊ើបអង្កេតជាមួយនគរបាលយុត្តិធម៌ នៅពេលមានបទល្មើសព្រហ្មទណ្ឌបានត្រូវប្រព្រឹត្តក្នុងន័យជៀសវាងប្រកាន់ឥរិយាបទបណ្តោយអោយនគរបាលយុត្តិធម៌ដើរតួនាទីជាអយ្យការជំនួសចំណែកខ្លួនឯងជ្រើសរើសដើរតួនាទីជាទីងមោង ដោយយកលេសថាអយ្យការគ្មានមធ្យោបាយធ្វើដំណើរ និងថវិកាដើម្បីបំពេញការងារ ។

ខ្ញុំសូមឆ្លៀតទាក់ទាញអារម្មណ៍លោកព្រះរាជអាជ្ញារងខ្លះ ពេលចុះស៊ើបអង្កេតជាមួយមន្ត្រីនគរបាលយុត្តិធម៌ កុំឆ្លៀតគៃបំបាត់នូវវត្ថុតាងដកហូត ជាប្រយោជន៍ផ្ទាល់ខ្លួនដែលជាអំពើប្រព្រឹត្តបទល្មើស ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០០០

**អគ្គព្រះរាជអាជ្ញា**

**ហង់រ៉ូ វ៉ាកេន**

<u>ចម្លងជូន</u>

-ឯកឧត្តម លោកជំទាវ ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
-ឯកឧត្តម លេខាធិការ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
-ដើម្បីជ្រាបជាព័ត៌មាន